មណ្ឌលសិក្សាឯកភាពហ្វ្រេស្ណូ ក្រុមអ្នកឯកទេស

# ក្រដាសអនុញ្ញាតពីឪពុកម្ដាយឲ្យសិស្សផ្ញើអ៊ីមែល
# គោលការណ៍បន្ថែមដែលអាចប្រើបាន

ឈ្មោះសិស្ស.................................................................................................ថ្ងៃខែ...............

សាលា............................................................................................................បន្ទប់...............

ជំរាបមកឪពុកម្ដាយ និងសិស្ស :
លិខិតនេះផ្ញើមកជំរាបលោកអ្នកថា គ្រូបង្រៀនកូនលោកអ្នកនឹងប្រើ អ៊ីមែល ដើម្បីដាក់ឲ្យសិស្សធ្វើកិច្ចការនៅក្នុងថ្នាក់រៀន។ ដោយសារសាលារៀនត្រូវបានទទួលបង្គាប់ឲ្យ សិស្សម្នាក់ៗត្រូវជ្រើសរើសអ៊ីមែលរៀងៗខ្លួននៅក្នុងតំបនសិក្សាយើងនេះ លោកអ្នកចាំបាច់ត្រូវធ្វើសំបុត្រអនុញ្ញាតឲ្យកូនលោកអ្នកក្នុងការប្រើអ៊ីមែលនេះ។

ការប្រើប្រាស់អ៊ីមែលរបស់សិស្សម្នាក់ៗដែលលោកអ្នកបានយល់ព្រមពីមុនមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងគោលការណ៍របស់តំបនសិក្សាហ្វ្រេស្ណូយើងទេ ដូច្នេះពាក្យសុំនេះធ្វើឡើងដើម្បីបន្ថែមទៅក្នុងសេចក្ដីយល់ព្រមរបស់តំបនសិក្សាកាលពីមុន ក្នុងការប្រើអ៊ិនធើណេត និងបណ្ដាញណែនាំ ដែលបានរៀបចំនៅក្នុងសៀវភៅពត៌មានសំរាប់ឪពុកម្ដាយ ឆ្នាំ ២០០៤-២០០៥ និងបណ្ដាញផ្សាយពត៌មានដូចតទៅនេះ : http://www.fresno.k12.ca.us./technology/bp.

ដោយមានការអនុញ្ញាតពីលោកអ្នក កូនលោកអ្នកនឹងត្រូវបានចាត់តាំងឲ្យប្រើឈ្មោះរបស់ខ្លួន ដើម្បីផ្ញើឬទទួល អ៊ីមែលឆ្លងកាត់តាមប្រព័ន្ធអ៊ីមែល ដែលត្រួតពិនិត្យដោយសាលារៀន។ បទបញ្ញត្តិទាំងអស់របស់តំបនសិក្សានៅតែជាធរមានដដែល ហើយអនុវត្តទៅលើច្បាប់ដែលបានបញ្ជាក់នៅក្នុងគោលការណ៍ដែលអនុញ្ញាតឲ្យប្រើបាននោះ។ គោលបំណងដែលបានធ្វើមកហើយនេះគឺចង់ឲ្យបានសេចក្ដីសុខ ផុតពីគ្រោះថ្នាក់ដល់អ៊ីមែលរបស់សិស្ស ទោះជាយ៉ាងនេះក៏ដោយ រឿងនេះអ្នកប្រើប្រាស់ត្រូវតែទទួលខុសត្រូវទៅតាមបទវិន័យរបស់សាលារៀន តាមការណែនាំរបស់គ្រូ និងបែបបទ ព្រមទាំងត្រូវរាយការណ៍អ្វីដែលមិនស្របក្នុងការប្រើប្រាស់ ឬក្រដាសស្នាមដែលមិនសមស្របដល់បុគ្គលិកសាលារៀន។

ដូចបានពន្យល់នៅក្នុងគោលការណ៍ឲ្យប្រើប្រាស់នេះរួចមកហើយ ការប្រើបច្ចេកទេសរបស់សាលា ការប្រើបណ្ដាញផ្សាយ និងអ៊ិនធើណេត មិនមែនបង្កើតនូវសិទ្ធិឯកជនតាមការសង្ឃឹមនោះទេ។ តំបនសិក្សាហ្វ្រេស្ណូរក្សាសិទ្ធិក្នុងការស្រាវជ្រាវនិងត្រួតពិនិត្យពត៌មានទាំងឡាយ ដែលបានបង្កើត បានប្រើ បានផ្ញើនិងទទួល ឬរក្សាទុក នៅក្នុងទ្រង់ទ្រាយណាក៏ដោយដែលសិស្សបានប្រើនៅក្នុងឧបករណ៍របស់សាលារៀននោះ។

ការចុះហត្ថលេខាខាងក្រោមនេះ មានន័យថាលោកអ្នកយល់និងយល់ព្រមតាមគោលការណ៍របស់តំបនសិក្សា ដែលមានលំអិតនៅក្នុងច្បាប់របស់ក្រុមប្រឹក្សាភិបាលក្រសួងអប់រំលេខ០៤៤០.១ និងលេខ៦១៦២.៧ ដូចខាងលើ និងបទបញ្ញត្តិបន្ថែមផ្នែករដ្ឋបាលរបស់ក្រសួងអប់រំនោះ។ដើម្បីនឹងអានគោលការណ៍ទាំងអស់នេះបាន លោកអ្នកត្រូវទាក់ទងជាមួយការិយាល័យសាលារៀនឬរកមើលក្នុងបណ្ដាញអ៊ិនធើណេតដូចតទៅនេះ www.fresno.k12.ca.us/technology/bp.

---------------------------------សូមគូសយកមួយ និងចុះហត្ថលេខានៅខាងក្រោម----------------------

................ខ្ញុំ**យល់ព្រម**ឲ្យកូនខ្ញុំប្រើអ៊ីមែលយោងតាមច្បាប់ដូចខាងលើ ដែលសាលាផ្ដល់ឲ្យ។
...............ខ្ញុំ**មិនយល់ព្រម**ឲ្យកូនខ្ញុំប្រើអ៊ីមែលយោងតាមច្បាប់ដូចខាងលើ ដែលសាលាផ្ដល់ឲ្យនោះទេ។

ហត្ថលេខាសិស្ស.................................ហត្ថលេខាឪពុកម្ដាយ.................................ថ្ងៃខែ................

Khmer PK-4866